# សេចក្តីសង្ខេបនៃ
# កិច្ចសន្ទនាពាណិជ្ជកម្មអឺរ៉ុប-អាស៊ាន
# នៅក្រសួងពាណិជ្ជកម្ម
# ភ្នំពេញ ថ្ងៃទី០៥ ខែមករា ឆ្នាំ២០១២

**វត្តមាន:**

ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

នាយក និងប្រតិភូអឺរ៉ុប

អង្គទូតនៃបណ្តាប្រទេសអឺរ៉ុប

វិស័យឯកជន

សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (លោក **វ៉ាន់ ស៊ូអៀង** លោក **Choon Yik Thong** លោក **Albert Tan** និងលោក **លី តេកហេង**)

**គោលបំណង:** បង្កើតគម្រោងគំនិតដល់វិស័យឯកជន ស្តីពីការភ្ជាប់ទំនាក់ទំនងពាណិជ្ជកម្មអឺរ៉ុប-អាស៊ានដែលនាំឲ្យមានការអភិវឌ្ឍសហគមន៍ពាណិជ្ជកម្មអាស៊ាន-អឺរ៉ុប និង កិច្ចប្រជុំក្រុមប្រឹក្សាពាណិជ្ជកម្មអឺរ៉ុប-អាស៊ានលើកទី២នាពេលខាងមុខ នៅកិច្ចប្រជុំកំពូលអឺរ៉ុប-អាស៊ាននៅថ្ងៃទី១ ខែមេសា ឆ្នាំ២០១២ រាជធានីភ្នំពេញ។

បន្ទាប់ពីកិច្ចស្វាគមន៍ប្រតិភូ និងភ្ញៀវទាំងអស់ ឯកឧត្តម **ចម ប្រសិទ្ធ** បានជម្រាបភ្ញៀវចូលរួមទាំងអស់អំពីភាពចាំបាច់នៃការមានវិស័យឯកជន ដែលដើរតួនាទីសំខាន់ក្នុងការពន្លឿនសមាហរណកម្មអាស៊ាន និងយកអត្ថប្រយោជន៍ពីគំនិតផ្តួចផ្តើមដែលផ្តល់ដោយសហគមន៍អឺរ៉ុប គឺការរួចពន្ធ និងការរួចកូតា។

ឯកឧត្តមបានថ្លែងថា វិស័យជាក់លាក់ផ្សេងៗនឹងត្រូវពិភាក្សាក្នុងចំណោមសមាជិកខ្លួនឯង ហើយដាក់នូវតម្រូវការ និងអនុសាសន៍របស់ខ្លួនដើម្បីដាក់មកក្រសួងសម្រាប់ការគាំទ្រ និងសម្របសម្រួល។ កាលពីឆ្នាំមុន ក្នុងអំឡុងកិច្ចប្រជុំកំពូលនៅទីក្រុងហ្សាកាតា (Jakarta) ចំណុចចំនួន៧ ត្រូវបានលើកឡើង ហើយពួកគេត្រូវការការឆ្លើយតបប្រកបដោយប្រសិទ្ធភាព ដែលជំរុញឲ្យមានកិច្ចសន្ទនាច្រើនជាងមុន។ ប្រទេសអាស៊ាននីមួយៗមានសភាពាណិជ្ជកម្មរបស់ខ្លួនដើម្បីចូលរួមគ្នាបង្កើតក្រុមប្រឹក្សាពាណិជ្ជកម្មអឺរ៉ុប-អាស៊ាន។

ក្នុងនាមជាប្រធានអាស៊ាន កម្ពុជានឹងទទួល**កិច្ចប្រជុំក្រុមប្រឹក្សាពាណិជ្ជកម្មអឺរ៉ុប-អាស៊ានលើកទី២នៅកិច្ចប្រជុំកំពូលអាស៊ាននៅរាជធានីភ្នំពេញ នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០១២** ខាងមុន ដែលក្នុងអំឡុងពេលនោះ ឧកញ៉ា **គិត ម៉េង** ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឯកឧត្តម **Karei de Gucht** ស្នងការពាណិជ្ជកម្មសហគមន៍អឺរ៉ុប ឯកឧត្តម **សុរិន ពិតសុវណ្ណ** (Surin Pitsuwan) អគ្គលេខាធិការ

អាស៊ាន នឹងថ្លែងសុន្ទរកថាទៅកាន់ភ្ញៀវចូលរួមទាំងអស់។ សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នឹងថ្លែងសុន្ទរកថាបើកកិច្ចប្រជុំកំពូលនោះ។

ជាងនេះទៅទៀត វិស័យជាក់លាក់នីមួយៗនឹងរៀបចំក្រុមរបស់ខ្លួន ហើយធ្វើការប្រើប្រាស់ការភ្ជាប់ទំនាក់ទំនងពាណិជ្ជកម្មទាំងអស់។ សម្រាប់វិស័យវាយនភ័ណ្ឌដែលជាសមាហរន្តកម្មពាណិជ្ជកម្មអាស៊ានចម្បង លោក **វ៉ាន់ ស៊ូអៀង** ប្រធានសមាគមរោងចក្រកាត់ដេរនៅកម្ពុជា នឹងត្រូវធ្វើការជាមួយសមាជិករបស់ខ្លួន និងមេដឹកនាំពាណិជ្ជកម្មពាក់ព័ន្ធទាំងអស់ដើម្បីពិភាក្សាបញ្ហាសក្តានុពលពាណិជ្ជកម្ម និងភាពជាដៃគូពាណិជ្ជកម្មរបស់ខ្លួន។ វិស័យឯកជននឹងផ្តោតចម្បងទៅលើភាពជោគជ័យពាណិជ្ជកម្មដើម្បីបង្ហាញឲ្យឃើញនូវភាពរីកចម្រើនខ្លាំងជាងមុនក្នុងបណ្តាប្រទេសអាស៊ានដែលកម្ពុជាអាចធ្វើបាន។ កម្ពុជាគឺជាទូកម៉ាស៊ីនលឿនតូចមួយដែលអាចធ្វើដំណើរទៅយ៉ាងលឿន។

  

តំណាងសហគមន៍អឺរ៉ុប :

វាជាសេចក្តីរីករាយណាស់ដែលមានព្រឹត្តិការណ៍បែបនេះត្រូវបានរៀបចំឡើងម្តងទៀតនៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា។ សហគមន៍អឺរ៉ុប គាំទ្រឲ្យមានការរៀបចំនេះ។ សភាពាណិជ្ជកម្មអឺរ៉ុប (EuroCham) គឺនៅវ័យក្មេងនៅឡើយ ហើយហេតុដូច្នេះត្រូវការការគាំទ្រទាំងអស់ដើម្បីធ្វើឲ្យព្រឹត្តិការណ៍នោះទទួលបានជោគជ័យ។ ពួកគេគាំទ្រគំនិតផ្តួចផ្តើមរបស់ឯកឧត្តមរដ្ឋមន្ត្រីក្នុងការធ្វើឲ្យពាណិជ្ជករទាំងអស់ ដឹងអំពីតួនាទីរបស់ខ្លួនក្នុងការភ្ជាប់ទំនាក់ទំនងពាណិជ្ជកម្មក្នុងចំណោមសហគមន៍អាស៊ាននិងអឺរ៉ុប ។ លោក **សឿន សុថា** (Soeun Sotha)នឹងរៀបចំកិច្ចជំនួបចាប់ដៃគូពាណិជ្ជកម្មនៅព្រឹកថ្ងៃទី២ ខែមេសា។

ឧកញ៉ា **គិត ម៉េង** គាំទ្រទាំងស្រុងចំពោះគំនិតផ្តួចផ្តើមនៃកិច្ចប្រជុំក្រុមប្រឹក្សាពាណិជ្ជកម្ម និងកិច្ចប្រជុំកំពូល នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០១២ ដែលនឹងលើកកម្ពស់ពាណិជ្ជកម្ម ជាពិសេសពាណិជ្ជកម្មក្នុងតំបន់ និងការទាក់ទាញការវិនិយោគមកកម្ពុជា និងអាស៊ាន។ វាផ្តល់នូវឱកាសសម្រាប់សហគមន៍អឺរ៉ុប ដើម្បីជំរុញ និងនាំមកនូវពាណិជ្ជកម្មអឺរ៉ុប ចំពោះកិច្ចប្រជុំកំពូលនោះ។ សភាពាណិជ្ជកម្មកម្ពុជានឹងរៀបចំខ្លួនជាស្រេចដើម្បីសម្របសម្រួលកិច្ចដោះដូរពាណិជ្ជកម្ម ដែលនឹងជាពេលសម្រាប់មេដឹកនាំពាណិជ្ជកម្មកម្ពុជាដឹងអំពីទ្រង់ទ្រាយពាណិជ្ជកម្មជាមួយសហគមន៍អឺរ៉ុប ។

ឯកឧត្តម **ចម ប្រសិទ្ធ** បានតែងតាំង ឯកឧត្តម **ប៉ាន់ សូរស័ក្តិ** រដ្ឋលេខាធិការនៃក្រសួងពាណិជ្ជកម្ម មើលការខុសត្រូវលើការរៀបចំទាំងមូលនៃព្រឹត្តិការណ៍នាពេលខាងមុខ។

កិច្ចប្រជុំបានបញ្ចប់នាវេលាម៉ោង៥:៣០នាទី។

**លោក តេក ហេង**